# ការសម្រេចបានវឌ្ឍនភាពៈ ការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធរបស់ចិនក្នុងតំបន់អាស៊ាន និងលើសពីនេះ

inclusive development international

## ព្រឹត្តិប័ត្រព័ត៌មានទី២ៈ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

ប្រទេសចិនបានប្រកាសអំពីផែនការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ក្នុងខែតុលា ឆ្នាំ២០១៣។ មួយឆ្នាំក្រោយមក ប្រទេសអាស៊ីចំនួន ២១ បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ដោយឯកភាពចូលរួម។ គិតត្រឹមខែមេសា ឆ្នាំ២០១៥ មានប្រទេសចំនួន ៥៧ បានចុះហត្ថលេខាជាសមាជិកស្ថាបនិក។ មូលនិធិដំបូងដែលត្រូវបានអនុម័តរបស់ AIIB មានទឹកប្រាក់ចំនួន ១០០ ពាន់លានដុល្លារអាមេរិក។ ភាគហ៊ុនធំជាងគេបំផុតនៅក្នុងធនាគារនេះគឺកាន់ដោយប្រទេសចិន ដែលមកទល់ពេលនេះមានចំណែកបោះឆ្នោតច្រើនជាងគេបំផុតក្នុងស្ថាប័នមួយនេះ។

ដោយមានការិយាល័យកណ្តាលនៅទីក្រុងប៉េកាំង ធនាគារនេះផ្តោតការយកចិត្តទុកដាក់ចំពោះការផ្តល់ហិរញ្ញប្បទានលើហេដ្ឋារចនាសម្ព័ន្ធ និង"វិស័យផលិតភាពដទៃទៀត" ក្នុងទ្វីបអាស៊ី។ វិស័យទាំងនេះរួមមានជាអាទិ៍ដូចជា វិស័យអគ្គិសនី និងថាមពល វិស័យដឹកជញ្ជូន និងទូរគមនាគមន៍ វិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងកសិកម្ម វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ វិស័យការពារបរិស្ថាន វិស័យអភិវឌ្ឍន៍ទីក្រុង និងឡូជីស្ទិក និងវិស័យដទៃទៀត។[1] គម្រោងដំបូងៗរបស់ធនាគារត្រូវបានប្រកាសនៅខែមេសា-ឧសភា ឆ្នាំ២០១៦ ដោយក្នុងនោះរួមមាន គម្រោងអគ្គិសនី ការដឹកជញ្ជូន និងការអភិវឌ្ឍទីក្រុង ក្នុងប្រទេសប៉ាគីស្ថាន តាជីគីស្ថាន បង់ក្លាដេស និងឥណ្ឌូនេស៊ី។ ក្រោយមក មានគម្រោងផ្សេងៗទៀតដែលត្រូវបានអនុម័តនៅក្នុងឆ្នាំដដែល។

### ដំណាក់កាលសំខាន់ៗនៃការវិវឌ្ឍន៍របស់ AIIB

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍ |
|---|---|
| ខែតុលា ឆ្នាំ២០១៣ | លោក Xi Jinping ប្រកាសផែនការបង្កើត AIIB។ |
| ខែតុលា ឆ្នាំ២០១៤ | ប្រទេសអាស៊ីចំនួន ២១ បានចុះហត្ថលេខាលើ MOU បង្កើត AIIB។ |
| ខែមេសា ឆ្នាំ២០១៥ | AIIB អនុម័តលើការដាក់ពាក្យសុំជាសមាជិករបស់ប្រទេសចំនួន ៥៧។ |
| ខែមិថុនា ឆ្នាំ២០១៥ | ពិធីចុះហត្ថលេខាលើអត្ថបទកិច្ចព្រមព្រៀងរបស់ AIIB។ |
| កញ្ញា-តុលា ឆ្នាំ២០១៥ | AIIB ធ្វើសេចក្តីព្រាងក្របខ័ណ្ឌការងារផ្នែកបរិស្ថាន និងសង្គម ដែលបានបោះពុម្ពផ្សាយ ហើយការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលត្រូវបានធ្វើឡើង។ |
| ខែមករា ឆ្នាំ២០១៦ | ពិធីបើកសម្ពោធ AIIB ត្រូវបានធ្វើឡើង ហើយធនាគារត្រូវបានប្រកាសឱ្យបើកធ្វើអាជីវកម្ម។ |
| ខែមករា ឆ្នាំ២០១៦ | គោលនយោបាយផ្តល់ព័ត៌មានជាសាធារណៈបណ្តោះអាសន្នត្រូវបានអនុម័ត។ |
| ខែកុម្ភៈ ឆ្នាំ២០១៦ | ក្របខ័ណ្ឌការងារផ្នែកបរិស្ថាន និងសង្គមត្រូវបានអនុម័ត។ |
| មេសា-ឧសភា ឆ្នាំ២០១៦ | AIIB ប្រកាសអំពីគម្រោងក្នុងជុំដំបូង។ |
| ខែមិថុនា ឆ្នាំ២០១៦ | កិច្ចប្រជុំប្រចាំឆ្នាំលើកទីមួយ ត្រូវបានធ្វើឡើងនៅទីក្រុងប៉េកាំង។ |

## សមាជិកភាពរបស់ AIIB

ប្រជាជាតិចំនួន ៥៧ បានចុះហត្ថលេខាជាសមាជិកស្ថាបនិករបស់ AIIB។ យោងតាមសម្ដីរបស់ប្រធានធនាគារនេះបានឱ្យដឹងថា គិតមកត្រឹមខែមិថុនា ឆ្នាំ ២០១៦ នេះ មានប្រទេសចំនួន ៣០ បន្ថែមទៀតកំពុងស្ថិតក្នុងបញ្ជីរង់ចាំចូលជាសមាជិក។[2] តារាងខាងក្រោមបង្ហាញអំពីបណ្ដាប្រទេសជាសមាជិកស្ថាបនិកបែងចែកទៅតាមក្រុមតំបន់។

### សមាជិកស្ថាបនិករបស់ AIIB

| **អាស៊ីបូព៌ា** | **អាស៊ីអាគ្នេយ៍** | **អាស៊ីកណ្ដាល** | **អាស៊ីខាងត្បូង** | **អាស៊ីខាងលិច** |
| --- | --- | --- | --- | --- |
| ចិន<br>ម៉ុងហ្គោលី<br>កូរ៉េខាងត្បូង | ប្រ៊ុយណេ<br>កម្ពុជា<br>ឥណ្ឌូនេស៊ី<br>ឡាវ<br>ម៉ាឡេស៊ី<br>មីយ៉ាន់ម៉ា<br>ហ្វីលីពីន<br>សឹង្ហបុរី<br>ថៃ<br>វៀតណាម | កាហ្សាស្ថាន<br>គីជីស្ថាន<br>តាជីគីស្ថាន<br>អ៊ូបេគីស្ថាន | បង់ក្លាដេស<br>ឥណ្ឌា<br>អៀរ៉ង់<br>ម៉ាល់ឌីវ<br>នេប៉ាល់<br>ប៉ាគីស្ថាន<br>ស្រីលង្កា | អាស៊ែបៃហ្សង់<br>ជ័រចៀ<br>អ៊ីស្រាអែល<br>ចំរដាន់<br>គុយវ៉ែត*<br>អូម៉ង់<br>កាតារ<br>រុស្ស៊ី<br>អារ៉ាប៊ីសាអូឌីត<br>ទួរគី<br>សហព័ន្ធអារ៉ាប់រួម |
| **អូសេអានី** | | | | |
| អូស្ត្រាលី<br>ញ៉ូវហ្ស៊ីលែនដ៍ | | | | |
| **អាមេរិក** | **អឺរ៉ុបខាងជើង** | **អឺរ៉ុបខាងត្បូង** | **អឺរ៉ុបខាងកើត** | **អឺរ៉ុបខាងលិច** |
| ប្រេស៊ីល | ដាណឺម៉ាក<br>ហ្វាំងឡង់ដ៍<br>អាយលែនដ៍<br>ន័រវេ<br>ស៊ុយអែត<br>ចក្រភពអង់គ្លេស | អ៊ីតាលី<br>ម៉ាល់តា<br>ព័រទុយហ្គាល់<br>អេស្ប៉ាញ | ប៉ូឡូញ | អូទ្រីស<br>បារាំង<br>អាឡឺម៉ង់<br>លុចសំបួរ<br>ហូឡង់<br>ស្វីស |
| **អាហ្វ្រិក** | | | | |
| អេហ្ស៊ីប<br>អាហ្វ្រិកខាងត្បូង | | | | |

■ សមាជិកក្នុងតំបន់ ■ សមាជិកក្រៅតំបន់

ប្រទេសចិនក្ដាប់ប្រមាណ ៣០% នៃភាគហ៊ុនរបស់ធនាគារ និងជាង ២៦% នៃចំណែកបោះឆ្នោត។ ប្រទេសឥណ្ឌា និងរុស្ស៊ី គឺជាភាគហ៊ុនធំជាងគេលំដាប់លេខរៀងទីពីរ និងទីបី។

## ភាគហ៊ុនកំពូលៗទាំង ១០ នៅក្នុង AIIB

| សមាជិក | មូលធនចុះបញ្ជី (ពាន់លានដុល្លារអាមេរិក) | ចំណែកបោះឆ្នោត |
|---|---|---|
| ចិន | 29.78 | 26.06% |
| ឥណ្ឌា | 8.37 | 7.51% |
| រុស្ស៊ី | 6.54 | 5.93% |
| អាល្លឺម៉ង់ | 4.48 | 4.15% |
| កូរ៉េខាងត្បូង | 3.74 | 3.50% |
| អូស្ត្រាលី | 3.69 | 3.46% |
| បារាំង | 3.38 | 3.19% |
| ឥណ្ឌូនេស៊ី | 3.36 | 3.17% |
| ប្រេស៊ីល | 3.18 | 3.02% |
| ចក្រភពអង់គ្លេស | 3.05 | 2.91% |

*ប្រភពព័ត៌មាន៖ AIIB (2015), China Daily (2015)*

ដូចយើងបានឃើញខាងលើហើយថា ចំណែកបោះឆ្នោតរបស់ចិននៅ AIIB គឺធំជាងសមាជិកណាៗទាំងអស់ ហើយធំជាងចំណែកបោះឆ្នោតបូកបញ្ចូលគ្នារបស់ប្រទេសឥណ្ឌា រុស្ស៊ី អាល្លឺម៉ង់ កូរ៉េខាងត្បូង និងអូស្ត្រាលី ដែលជាភាគហ៊ុនធំបន្ទាប់ទាំងប្រាំថែមទៀតផង។

## ការផ្តោតការយកចិត្តទុកដាក់តាមវិស័យ និងគោលវិធីរបស់ AIIB

គោលបំណងរបស់ AIIB ដែលត្រូវបានលើកឡើងគឺដើម្បី៖

1. ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព បង្កើតធនធាន និងធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងទ្វីបអាស៊ី តាមរយៈការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងវិស័យផលិតភាពដទៃទៀត និង
2. លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងតំបន់ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមផ្នែកការអភិវឌ្ឍ តាមរយៈការធ្វើការងារក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគីដទៃទៀត។[3]

លោកប្រធានធនាគារ AIIB បានបញ្ជាក់ថា ធនាគារនឹងប្រកាន់យកអត្ថន័យទូលំទូលាយសម្រាប់ពាក្យ "ហេដ្ឋារចនាសម្ព័ន្ធ"។ បន្ថែមលើការគាំទ្រចំពោះគម្រោងនានាដូចជាការដឹកជញ្ជូន ថាមពល និងទូរគមនាគមន៍ហើយនោះ ធនាគារក៏នឹងអាចវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជាវិស័យសុខាភិបាល

និងកិច្ចការពារបរិស្ថានផងដែរ។[4] ធនាគារអាចប្រើប្រាស់យន្តការផ្សេងៗជាច្រើន ដើម្បីចែកចាយមូលនិធិរបស់ខ្លួន រួមមានទាំងតាមរយៈកម្ចី ការវិនិយោគលើភាគហ៊ុន (ការទិញភាគហ៊ុន) ការធានាកម្ចី និងការផ្តល់ជំនួយផ្នែកបច្ចេកទេសជាដើម។ AIIB នឹងគាំទ្រយ៉ាងសកម្មឱ្យមានការចូលរួមជាមួយវិស័យឯកជន។[5]

គិតមកត្រឹមខែកញ្ញា ឆ្នាំ២០១៦ ធនាគារបានអនុម័តនូវគម្រោងចំនួនប្រាំមួយដែលខ្លួននឹងផ្តល់ហិរញ្ញប្បទានគាំទ្រ ដោយក្នុងនោះរួមមានគម្រោងចំនួនប្រាំដែលធនាគារសហការផ្តល់ហិរញ្ញប្បទានរួមជាមួយធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត។ មានគម្រោងចំនួនប្រាំពីរទៀត ដែលកំពុងត្រូវបានត្រួតពិនិត្យ។[6]

## គម្រោងរបស់ AIIB ដែលត្រូវបានប្រកាសគិតមកត្រឹមខែកញ្ញា ឆ្នាំ២០១៦

| ប្រទេស | គម្រោង | តម្លៃ | សំគាល់ |
|---|---|---|---|
| ប៉ាគីស្ថាន | គម្រោងសាងសង់ផ្លូវជាតិហាយវេ M4 | $273 លាន | សហអ្នកផ្តល់ហិរញ្ញប្បទាន រួមជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DfID) របស់ចក្រភពអង់គ្លេស។ |
| តាជីគីស្ថាន | គម្រោងធ្វើឱ្យប្រសើរឡើងនូវផ្លូវ Dushanbe-Uzbekistan | $106 លាន | សហអ្នកផ្តល់ហិរញ្ញប្បទាន រួមជាមួយធនាគារអឺរ៉ុបសម្រាប់ការស្តារ និងអភិវឌ្ឍ។ |
| បង់ក្លាដេស | គម្រោងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយថាមពល | $262 លាន | អនុវត្តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីជនបទរបស់បង់ក្លាដេស និងក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនី Dhaka។ |
| ឥណ្ឌូនេស៊ី | គម្រោងថ្នាក់ជាតិដើម្បីកែលម្អតំបន់អាណាធិបតេយ្យ | $216.5 លាន | សហអ្នកផ្តល់ហិរញ្ញប្បទាន រួមជាមួយធនាគារពិភពលោក។ |
| ប៉ាគីស្ថាន | គម្រោងពង្រីកថាមពលវារីអគ្គិសនី Tarbela 5 | $300 លាន | សហអ្នកផ្តល់ហិរញ្ញប្បទាន រួមជាមួយធនាគារពិភពលោក។ |
| មីយ៉ាន់ម៉ា | គម្រោងរោងចក្រថាមពលឧស្ម័នទុរប៊ីន Myingyan | $២០ លាន | សហអ្នកផ្តល់ហិរញ្ញប្បទាន រួមជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី។ |

## រចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់ AIIB

AIIB មានរចនាសម្ព័ន្ធគ្រប់គ្រងជាបីថ្នាក់រួមមាន៖ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សានាយក និងប្រធានម្នាក់។[7] ខុសប្លែកពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារ AIIB ពុំមានក្រុមប្រឹក្សាភិបាលនិវាសដ្ឋានឡើយ។ ផ្ទុយមកវិញ ក្រុមប្រឹក្សារបស់ AIIB ជួបប្រជុំគ្នាជាទៀងទាត់ តាមរយៈសន្និសីទវីដេអូ។

បច្ចុប្បន្ន ក្រុមប្រឹក្សាអនុម័តលើគម្រោងទាំងអស់ ប៉ុន្តែនាពេលអនាគត AIIB គ្រោងនឹងធ្វើប្រតិភូកម្មអំណាចក្នុងការសម្រេចចិត្តទៅឱ្យថ្នាក់គ្រប់គ្រងធនាគារ។[8] ចំណែកនៅឯធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី រាល់គម្រោងថ្មីៗទាំងអស់ ត្រូវមានការអនុម័តពីក្រុមប្រឹក្សា។ ការធ្វើបែបនេះ អនុញ្ញាតិឱ្យមានការរក្សាតុល្យភាពអំណាច និងដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធគណនេយ្យភាពក្នុងស្ថាប័នទាំងពីរនេះ។ ក្រាហ្វិចព័ត៌មានខាងក្រោម បង្ហាញអំពីរចនាសម្ព័ន្ធ និងការក្តាប់ភាគហ៊ុនរបស់ធនាគារ។




*ប្រភពព័ត៌មាន៖ South China Morning Post (2015)*

## ការប្តេជ្ញាចិត្តរបស់ AIIB ដើម្បីធានាតម្លាភាព និងការប្រឆាំងអំពើពុករលួយ

ប្រធាន AIIB បានសង្កត់ធ្ងន់នូវការប្តេជ្ញាចិត្តរបស់ AIIB ក្នុងការរក្សាភាព "ស្អាតស្អំ" ហើយបានប្តេជ្ញាចិត្តបង្កើតវប្បធម៌ស្ថាប័នដ៏រឹងមាំ ដោយផ្អែកលើបទដ្ឋានសីលធម៌។ លោកក៏បានលើកឡើងនៅក្នុងឱកាសជាច្រើនថា ធនាគារនឹងប្រកាន់យក "ឥរិយាបទមិនអធ្យាស្រ័យដាច់ខាត" ចំពោះអំពើពុករលួយ។[9]

គោលនយោបាយផ្តល់ព័ត៌មានជាសាធារណៈបណ្តោះអាសន្ន ត្រូវបានអនុម័តនៅខែមករា ឆ្នាំ ២០១៦។ គោលនយោបាយនេះ តម្រូវឱ្យធនាគារត្រូវចេញផ្សាយទាំងព័ត៌មានផ្នែកស្ថាប័ន និងព័ត៌មានផ្នែកប្រតិបត្តិការ លើកលែងតែមាន "ហេតុផលរឹងមាំសម្រាប់ការរក្សាការសម្ងាត់"។[10] សំខាន់ជាងនេះទៀត គោលនយោបាយបញ្ជាក់ថា នឹងបោះពុម្ពផ្សាយឯកសារការវាយតម្លៃបរិស្ថាន និងសង្គមសំខាន់ៗ។[11] ការបើកចំហរឯកសារទាំងអស់នេះមានភាពចាំបាច់ណាស់ ប៉ុន្តែគោលនយោបាយនេះខ្វះភាពច្បាស់លាស់អំពីការកំណត់ពេលវេលាសម្រាប់ការបើកចំហរឯកសារទាំងនេះ ជាពិសេសគឺ តើព័ត៌មាននោះនឹងត្រូវផ្សព្វផ្សាយ នៅពេលគម្រោងកំពុងស្ថិតក្រោមការពិចារណា ឬចំពោះតែក្រោយពេលបានទទួលការអនុម័តរួចហើយ។

ធនាគារក៏ត្រូវបានតម្រូវឱ្យបង្កើតយន្តការមួយ ដើម្បីមើលខុសត្រូវលើការគ្រប់គ្រង និងប្រតិបត្តិការរបស់ធនាគារផងដែរ។[12] តួនាទីមើលការខុសត្រូវនេះ នឹងត្រូវអនុវត្តដោយនាយកដ្ឋានអនុលោមភាព ប្រសិទ្ធភាព និងសុច្ចរិតភាព ដែលត្រូវបានបង្កើតឡើងរួចហើយ ប៉ុន្តែកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍបន្ថែមទៀត នៅពេលសរសេរអត្ថបទនេះ។

## ការធានាសុវត្ថិភាពផ្នែកបរិស្ថាន និងសង្គម

នៅខែកុម្ភៈ ឆ្នាំ២០១៦ AIIB បានអនុម័តលើក្របខ័ណ្ឌការងារផ្នែកបរិស្ថាន និងសង្គម (ESF) របស់ខ្លួន ដែលចែងអំពីបទដ្ឋាន និងគោលនយោបាយដែលគួរអនុវត្តនៅក្នុងគម្រោងផ្តល់ហិរញ្ញប្បទានដោយ AIIB ។ ក្របខ័ណ្ឌការងារនេះនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពក្រោយរយៈពេលបីឆ្នាំ។[13] ESF ចែងអំពីការតម្រូវជាកាតព្វកិច្ចចំពោះគម្រោងនីមួយៗ រួមទាំងបទដ្ឋានផ្នែកបរិស្ថាន និងសង្គមចំនួនបី ស្តីពីការវាយតម្លៃ និងការគ្រប់គ្រងគម្រោង ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និងជនជាតិដើមភាគតិច។

ESF ផ្ទុកនូវពាក្យពេចន៍គួរជាទីសង្ឃឹមមួយចំនួន ដោយបានបញ្ជាក់ថា AIIB អនុវត្តតាមគោលការណ៍ការអភិវឌ្ឍប្រកបដោយនិរន្តរភាព មានការចូលរួម ការពង្រឹងអំណាចប្រជាជនមូលដ្ឋាន និងការចូលរួមជាមួយសាធារណ។ ប៉ុន្តែ បើទោះបីជាមានចក្ខុវិស័យបែបរីកចម្រើនយ៉ាងនេះក្តី ក៏យើងឃើញថា ESF ក៏នៅមានចំណុចខ្សោយ និងចន្លោះប្រហោងមួយចំនួនផងដែរ។ សំណៅព្រាងរបស់ឯកសារនេះត្រូវបានផ្តល់ជូននៅខែកញ្ញា ឆ្នាំ២០១៥ ហើយក្រុមសង្គមស៊ីវិលក៏បានទទួលឱកាសដ៏ខ្លីក្នុងការផ្តល់មតិយោបល់ផងដែរ។ នៅក្នុង ESF ដែលត្រូវបានអនុម័ត មានដាក់បញ្ចូលការកែលម្អលើផ្នែកសំខាន់ៗជាច្រើន បន្ថែមពីលើសេចក្តីព្រាងទីមួយ ដោយបានឆ្លើយតបទៅនឹងកង្វល់ដែលសង្គមស៊ីវិលបានលើកឡើង ប៉ុន្តែឯកសារនេះក៏នៅតែមានចំណុចខ្សោយចម្បងៗមួយចំនួននៅឡើយ។

ទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅ AIIB បញ្ជាក់ថាខ្លួននឹងមិនផ្តល់ហិរញ្ញប្បទានដោយចេតនា ដល់គម្រោងទាំងឡាយណាដែលមានពាក់ព័ន្ធ ឬបណ្តាលឱ្យកើតមានការបណ្តេញចេញដោយបង្ខំនោះឡើយ ដែលនេះជាការប្តេជ្ញាចិត្តមួយគួរឱ្យកោតសរសើរ។ នៅក្រោមក្របខ័ណ្ឌការងារនេះ ការបណ្តេញចេញអាចធ្វើឡើងបានតែនៅក្នុង "លក្ខណៈមួយអនុលោមតាមគោលការណ៍ជាមូលដ្ឋាននៃនីតិវិធីច្បាប់ត្រឹមត្រូវ" ប៉ុណ្ណោះ។ ទោះយ៉ាងណាក្តី និយមន័យនៃការបណ្តេញចេញដោយបង្ខំនៅក្រោមក្របខ័ណ្ឌការងារនេះ មិនបានដាក់បញ្ចូលនូវការបណ្តេញចេញ ដែលត្រូវបានធ្វើឡើងតាមរយៈការអនុវត្តសិទ្ធិអស្សាមិករណ៍ ឬការធ្វើលទ្ធកម្មដីធ្លីជាកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ជាតិនោះឡើយ។ បញ្ហានេះបានកើតឡើង បើទោះបីជាច្បាប់របស់ប្រទេសជាសមាជិក AIIB ជាច្រើន ពុំមានបទប្បញ្ញត្តិរឹងមាំដើម្បីធានាថា គម្រោងដែលបង្កឱ្យមានការជម្លៀសប្រជាពលរដ្ឋ ពិតជាលើកកម្ពស់សុខមាលភាពទូទៅយ៉ាងពិតប្រាកដ ឬធានាថាការជម្លៀសប្រជាពលរដ្ឋ និងហានិភ័យពាក់ព័ន្ធ មានភាពសមហេតុផល និងមានសមាមាត្រទៅនឹងប្រយោជន៍សាធារណៈដែលកើតចេញពីការជម្លៀសនេះក៏ដោយ។

បទដ្ឋានដែលមានចេតនាជួយការពារសិទ្ធិ និងផលប្រយោជន៍របស់ជនជាតិដើមភាគតិច បង្កើតនូវបទដ្ឋានគោលទាបជាងបទដ្ឋានរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត។ អ្វីដែលគួរជាទីបារម្ភបំផុតនោះគឺច្បាប់ចុងក្រោយនៃបទដ្ឋាននេះ បានដកចេញនូវការលើកឡើងស្តីពីតម្រូវការចាំបាច់ក្នុងការធានាឱ្យមានការយល់ព្រមដោយសេរីជាមុនដោយផ្អែកលើការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) ដែលមាននៅក្នុងច្បាប់មុននៃឯកសារនេះ ហើយដាក់ជំនួសមកវិញដោយទស្សនាទានស្តីពីការ*ពិគ្រោះយោបល់* ដោយសេរីជាមុន និងផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ (FPICon) ដែលត្រូវបានកំណត់និយមន័យយ៉ាងអន់បំផុត។ បទដ្ឋាននេះ ជាបទដ្ឋានមិនសូវមានភាពម៉ត់ចត់ ហើយផ្តល់សិទ្ធិដល់ជនជាតិដើមភាគតិច តិចជាងសិទ្ធិដែលមាននៅក្នុងបទដ្ឋាន FPIC។

ESF លើកឡើងអំពីយន្តការឃ្លាំមើលមួយ ដែលប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងបាន ប្រសិនបើពួកគេជឿជាក់ថាពួកគេបានរងផលប៉ះពាល់អវិជ្ជមាន ឬទំនងជានឹងរងផលប៉ះពាល់អវិជ្ជមាន ដោយសារតែការខកខានរបស់ធនាគារក្នុងការអនុវត្តក្របខ័ណ្ឌការងារនេះ។[14] នៅក្នុងពេលសរសេរអត្ថបទនេះ AIIB បានចាត់តាំងឱ្យមានប្រធានអង្គភាពនេះហើយ ប៉ុន្តែគោលនយោបាយប្រតិបត្តិការរបស់អង្គភាពនេះនៅមិនទាន់បានអនុម័តនៅឡើយ ហើយអង្គភាពក៏នៅមិនទាន់មានបុគ្គលិកពេញលេញដែរ។ ដូចគ្នានឹងយន្តការបណ្តឹងរបស់ស្ថាប័នហិរញ្ញវត្ថុដទៃទៀតដែរ វាជាការចាំបាច់ណាស់ដែលត្រូវមានយន្តការឃ្លាំមើលដ៏រឹងមាំមួយ ដើម្បីធ្វើឱ្យធនាគារមានគណនេយ្យភាព។ យន្តការប្រភេទនេះ អាចជួយការពារសុវត្ថិភាពពីគ្រោះថ្នាក់នានាសម្រាប់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង ឬជួយសម្របសម្រួលការផ្តល់សំណងក្នុងករណីមានគ្រោះថ្នាក់កើតឡើង។

## អន្តរទំនាក់ទំនងរវាង AIIB និងស្ថាប័នហិរញ្ញវត្ថុដទៃទៀត

ប្រទេសចិន ចង់សង្កត់ធ្ងន់ឱ្យឃើញថា AIIB នឹងជួយបំពេញបន្ថែមលើការងាររបស់ស្ថាប័នហិរញ្ញវត្ថុពហុភាគីដែលមានស្រាប់ ជាជាងដើរតួជាគូប្រជែងរបស់ស្ថាប័នទាំងនោះ។ ដោយសារតែធនាគារនេះជាស្ថាប័នថ្មី ហើយនៅត្រូវជ្រើសរើសបុគ្គលិកពេញសិទ្ធិដើម្បីដំណើរការ និងគ្រប់គ្រងប្រតិបត្តិការណ៍ AIIB ចង់រកឱកាស ដើម្បីធ្វើជាសហអ្នកផ្តល់ហិរញ្ញប្បទានក្នុងគម្រោងនានាជាមួយស្ថាប័នដែលមានស្រាប់។ នៅឆមាសទីមួយនៃឆ្នាំ២០១៦ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារអឺរ៉ុបសម្រាប់ការស្តារ និងអភិវឌ្ឍ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ AIIB ដើម្បីស្វែងរកឱកាសធ្វើការផ្តល់ហិរញ្ញប្បទានរួមគ្នា។ ថ្នាក់ដឹកនាំរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាហ្វ្រិក ធនាគារអភិវឌ្ឍន៍អ៊ីស្លាម និងធនាគារអភិវឌ្ឍន៍ថ្មី ក៏បានបង្ហាញចំណាប់អារម្មណ៍ចង់ធ្វើសហប្រតិបត្តិការផងដែរ។ នៅពេលកំពុងសរសេរអត្ថបទនេះ គម្រោងប្រាំក្នុងចំណោមគម្រោងដែលបានអនុម័តហើយទាំងប្រាំមួយរបស់ធនាគារ គឺជាគម្រោងទទួលការផ្តល់ហិរញ្ញប្បទានរួមគ្នា។

ការរៀបចំផ្តល់ហិរញ្ញប្បទានរួមគ្នានេះ មានអត្ថន័យ និងសក្តានុពលគួរជាទីកត់សម្គាល់យ៉ាងខ្លាំង។ យើងឃើញថា ការចូលរួមបន្ថែមរបស់ AIIB នឹងបង្កើនហិរញ្ញវត្ថុដែលមាន ដែលអាចជួយបំពេញចន្លោះខ្វះខាតដែលមាននាពេលបច្ចុប្បន្ន។ ការដាក់បញ្ចូលនូវមូលធនពី AIIB នឹងអនុញ្ញាតិឱ្យធនាគារទាំងឡាយអាចដាក់ធនធានរួមបញ្ចូលគ្នា ដែលជាការជួយសម្រួលដល់ការចាប់យកនូវគម្រោងធំៗថែមទៀត និងជួយរំលែកនូវហានិភ័យផ្នែកហិរញ្ញវត្ថុ។ ជាងនេះទៀត ក្នុងករណីដែលគម្រោង AIIB ចូលរួមផ្តល់ហិរញ្ញប្បទានជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត បទដ្ឋានផ្នែកសង្គម និងបរិស្ថាន ឬគោលនយោបាយការពារសុវត្ថិភាពរបស់ស្ថាប័នទាំងនោះ ទំនងជាត្រូវយកមកអនុវត្ត ហើយប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងនឹងមានលទ្ធភាពចូលទៅប្រើប្រាស់យន្តការបណ្តឹងរបស់ស្ថាប័នទាំងនោះ។

## សន្និដ្ឋាន

AIIB គឺជាស្ថាប័នហិរញ្ញវត្ថុពហុភាគីដឹកនាំដោយប្រទេសចិនដំបូងគេបំផុត ហើយធនាគារនេះកំពុងផ្សព្វផ្សាយខ្លួនឯងថាជាគំរូថ្មីមួយ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចកាន់តែមានប្រសិទ្ធភាពប្រសិទ្ធិផល និងសក្តិសមសម្រាប់សេចក្តីត្រូវការរបស់អាស៊ី។ ទ្វីបអាស៊ីជួបប្រទះបញ្ហាកង្វះហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់សម្រាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ រដ្ឋាភិបាលនៅក្នុងតំបន់នេះទាំងមូល បង្ហាញយ៉ាងច្បាស់នូវក្តីប្រាថ្នាចង់ទាក់ទាញការវិនិយោគទ្រង់ទ្រាយធំលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសលើវិស័យដឹកជញ្ជូន ថាមពល និងគម្រោងដទៃទៀតដែលជួយសម្របសម្រួលដល់ការតភ្ជាប់ទំនាក់ទំនង។ AIIB នឹងចូលរួមវិភាគទានក្នុងការឆ្លើយតបចំពោះសេចក្តីត្រូវការនេះ។ ជាក់ស្តែង លទ្ធភាពទទួលបានហិរញ្ញប្បទានកាន់តែច្រើននេះ ត្រូវបានប្រជាជាតិជាច្រើនបង្ហាញការស្វាគមន៍ ដូចបានស្តែងចេញតាមរយៈកំណើនយ៉ាងឆាប់រហ័សនៃចំនួនសមាជិកធនាគារ។ ក្នុងនាមជាស្ថាប័នថ្មីមួយ AIIB នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីអភិវឌ្ឍសមត្ថភាពផ្នែកស្ថាប័ន និងគោលនយោបាយប្រតិបត្តិការរបស់ខ្លួន។ ស្របពេលដែលធនាគារនេះមានការអភិវឌ្ឍឈានទ្បើង អ្នកសង្កេតនានានឹងត្រូវឃ្លាំមើលដោយយកចិត្តទុកដាក់ ថាតើគម្រោងជុំដំបូងរបស់ធនាគារនេះត្រូវបានអនុវត្តដោយរបៀបណា និងថាតើ AIIB ទទួលបានលទ្ធផលការងារកម្រិតណាក្នុងការអនុវត្តបទដ្ឋានសង្គម និងបរិស្ថាន។

*ព្រឹត្តិប័ត្រព័ត៌មាននេះដកស្រង់ចេញពីរបាយការណ៍អង្គការ Inclusive Development International ដែលមានចំណងជើងថា Making Inroads: Chinese Infrastructure Investment in ASEAN and Beyond ។*

*ការស្រាវជ្រាវនិងការអភិវឌ្ឍឯកសារបោះពុម្ពផ្សាយនេះបានទទួលការគាំទ្រពី Heinrich-Böll-Stiftung South East Asia,The McKnight Foundation and Planet Wheeler Foundation*

*ការបោះពុម្ពផ្សាយនេះបានទទួលអាជ្ញាប័ណ្ណអនុញ្ញាតក្រោម Creative Commons Attribution-NonCommercial-ShareAlike 4.0 International License*

---

[1] AIIB, *Articles of Agreement*, article 4.
[2] Li, X. (2016, 31 May), *AIIB will have 100 countries as members by year-end: JinLiqun*, ចិនDaily. http://europe.ចិនdaily.com.cn/business/2016-05/31/content_25555463.htm (accessed May 2016).
[3] AIIB (2015), *Articles of Agreement*, article 1.
[4] Hou, L. (2015, 20 September), *AIIB Vows to Engage Private Sector in Asia's Infrastructure Investment*, CRI English. http://english.cri.cn/12394/2015/09/20/2202s896811.htm (accessed May 2016).
[5] Xinhua (2015, 21 September), *AIIB vows to engage private sector across world in Asia's infrastructure investment*, China Daily. http://www.chinadaily.com.cn/business/2015-09/21/content_21937599.htm (accessed May 2016).
[6] AIIB (2015), *Projects*. http://www.aiib.org/html/PROJECTS/ (accessed May 2016).
[7] AIIB (2015), *Articles of Agreement*, article 21.
[8] AIIB (2016), *Operational Policy on Financing*, article 3.5.1.
[9] Xinhua (2015, 23 March), *AIIB to have zero-tolerance for corruption: official*, Xinhuanet. http://news.xinhuanet.com/english/2015-03/22/c_134087672.htm (accessed May 2015).
[10] AIIB (2016), *Public Information Interim Policy*, article 4.
[11] AIIB (2016), *Public Information Interim Policy*, article 7.
[12] AIIB (2015), *Articles of Agreement*, article 26.
[13] AIIB (2016), *Environmental and Social Framework*, para 4.
[14] AIIB (2016), *Environmental and Social Framework*, para 64.